**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍ នៅលើផ្លូវជាតិលេខ៤ ត្រង់ចំណោតអូរគ្រាវ ឃុំបិតត្រាង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានក្តីរន្ធត់ និងក្រៀមក្រំយ៉ាងក្រៃលែង ដោយទទួលបានដំណឹងថា កាលពីវេលាម៉ោង ៦:៣០ ល្ងាច ថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ នេះមានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរណ៍មួយបានកើតឡើង នៅលើផ្លូវជាតិលេខ៤ នៅត្រង់ចំណោតអូរគ្រាវ ឃុំបិតត្រាង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ចំពោះបងប្អូនកម្មករ កម្មការិនី ដែលបម្រើការងារនៅតំបន់សេដ្ឋកិច្ចពិសេសខេត្តព្រះសីហនុ។ គិតត្រឹមម៉ោង ៩:០០ នាទីព្រឹកនេះ មានកម្មករ កម្មការិនីរងរបួសចំនួន២៨នាក់ ក្នុងនោះរបួសធ្ងន់៣នាក់ បានបញ្ជូនមកមន្ទីរពេទ្យកាល់ម៉ែត អ្នករងរបួសស្រាល២៤នាក់ កំពុងសម្រាកព្យាបាលរបួសនៅតាមមន្ទីរពេទ្យនានាក្នុងខេត្តព្រះសីហនុ និងស្លាប់អ្នកបើកបរ១នាក់។ បច្ចុប្បន្នបេឡាជាតិរបបសន្តិសុខសង្គមរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងសហការជាមួយក្រុមគ្រូពេទ្យ និងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបន្តតាមដានការពិនិត្យព្យាបាលបងប្អូនកម្មករ កម្មការិនីទៅតាមស្ថានភាពរបស់អ្នករងរបួសនីមួយៗ។

ឆ្លៀតក្នុងឱកាសដ៏សែនក្រៀមក្រំនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសព និងជនរងគ្រោះ ហើយសូមបួងសួងដល់វិញ្ញាណក្ខន្ធអ្នកទទួលមរណភាពបានសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ និងសូមជូនពរឱ្យអ្នកដែលរងរបួសឆាប់បានជាសះស្បើយ។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងខិតខំដោះស្រាយទុក្ខលំបាករបស់បងប្អូនកម្មករ កម្មការិនី និងក្រុមគ្រួសារឱ្យបានជាអតិបរមា ទៅតាមគោលរបបសន្តិសុខសង្គមរបស់បេឡាជាតិរបបសន្តិសុខសង្គម។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩